# Adolescent and Youth Sexual Reproductive Health

Data from the secondary analysis of 2000 - 2014 Cambodia Demographic and Health Surveys

## Introduction

With 21.6% of the total population of **14.6 million** aged between 15 and 24 years (CIPS, 2013), Cambodia has the youngest population in Southeast Asia. While young people are the **greatest resource and hope** for socio-economic growth and development, many of them face serious challenges including **sexual and reproductive health (SRH) issues** exacerbated by a lack of SRH information, **knowledge, and youth friendly** services; low education attainment; and migration. Today, more young people are **sexually active** and the current marriage rate amongst 15-24 years old **has increased**. However, while there has been a gradual decline in the number of **sexually active young women NOT using contraception**, limited evidence is available on the SRH of adolescents and youth. This factsheet describes key findings on youth's practices associated with SRH, **contraceptive use**, and their knowledge about sexually transmitted infections (STIs) and HIV/AIDS.

*Definitions:*

*Adolescent: A population group aged from 10 to 19 (WHO).*

*Youth: Young people aged from 15 to 24.*

*Most-at-risk young people: Groups of young people at higher risk of disadvantage aged from 15 to 30.*

Percentage of young women aged 15 to 24 years who had been married by exactly years of age.




## Key SRH concerns for Adolescents and Youth

- The marriage rate amongst 15-24 year olds has increased for both sexes (**25.8%** in 2000 to **38.7%** in 2014 for women, and **16.5%** in 2005 to **19.0%** in 2014 for men).
- The proportion of currently married young women aged 15-17 years remained consistent at around **4-6%** across the four surveys.
- Limited knowledge about the methods and misconceptions about side effects, social and cultural norms, and women's traditional lack of power in relationships have contributed to low use of modern contraception.
- **37.7%** of males and **18.5%** of females among most-at-risk young people aged 10-24 years had sexual intercourse in the past three months.
  - Of this group, **69.6%** of males and **52.5%** of females engaged in commercial sex.
  - Furthermore, ONLY **43.3%** of males and **6.5%** of females reported always using condom with unpaid regular sexual partners.

Percentage of sexually active most-at-risk young people aged 10-24 engaged in commercial sex.




Age-specific fertility rates (ASFR) in urban and rural young women by age group, 2000 - 2014.




## Adolescent Fertility

- Adolescent fertility has **declined** in urban areas but increased in rural areas:
  - More than 33% of rural women aged 15-24 had begun child-bearing in 2014.
  - Phnom Penh had the **lowest national rate** and the Plateau/Mountain region had the **highest rate** in 2014.
- The number of women with no education who began child-bearing doubled between 2000 and 2014, while the number with higher education **nearly halved**.

The distribution of contraception methods used by young women aged 15-24 who have had sex.




## SRH Practices and Implications

- Less than **1%** of females who have never been married reported having had sex between 2000 and 2014.
- In 2005, only **1.8%** of unmarried males aged 15-17 years **reported having had sex** - among 18-19 year-olds the rate was **9.6%** and among 20-24 year-olds was **27.2%**.
- Childbirth among unmarried adolescent mothers is more likely to be **unintended** and result in **an induced abortion**.
- Unmarried adolescent mothers suffer increased rates of **anaemia, malaria, HIV** and STIs, postpartum haemorrhage, obstetric fistula and mental illness.
- **Sexual intercourse prior to marriage** among **females** is rare but there is a steady increase in pre-marital sex with age among young males.
- Young adolescent girls' immature reproductive and immune systems make them more susceptible to STIs and HIV transmission. **Pregnancy and delivery for girls** whose bodies are not yet fully-grown exposes them to **problems** which are less common in adult women.

## Family Planning

- There has been a chang in contraceptive use among sexually active young women aged 15-19 years & 20-24 years between 2000 & 2014.
- 12% of women aged 20 to 24 years were using a modern method in 2000, compared with 33%, in 2014.
- In 2000, **3%** of women aged 20-24 years used a traditional method, and **13%** in 2014.
- Unmet need for family planning is much more likely to be reported by ever-married women aged 15-24 years compared with their NEVER-married women counterparts.
- The proportion of ever-married women aged 15-24 years who reported an unmet need for family planning was close to 30% across all age ranges (15-17, 18-19 and 20-24 years) in 2014.
  - However, this has dropped to **5.6%** for women aged 15-17, **1.8%** for 18-19 years and **2.3%** for 20-24 years in 2014.

Mean age of last sexual partner of young women by age group between 2010 and 2014.




## Last Sexual Partner

- As a woman's age increases, the difference of age between her and her partner decreases.
- On average, there is a six-year age difference between sexually active 15-17 year-old females and their **most recent sexual partner** and a four-year difference for 20-24 year-old females.
- Women almost exclusively reported that their **most recent sexual partner was** their spouse or cohabiting partner, compared with ONLY three quarters of young males.

## Knowledge of Sexually Transmitted Diseases, HIV/AIDS and Condom Use

Percentage of young women aged 15 to 24 years who have a comprehensive knowledge about the risk factors for HIV.




- The percentage of men who reported a sex worker as being their most recent sexual partner decreased from 17.3% in 2005 to 2.2% in 2014.
- The percentage of condom usage during last sexual intercourse among young men aged 15-24 years has decreased significantly.
  - In 2005, **57.7%** of young men in urban areas and **23.3%** in rural areas used a condom during last intercourse; by 2014, this dropped to **57.2%** in urban and **10.3%** in rural areas.


Phnom Penh Centre (North Building), 5th Floor, Room 526, Tonle Bassac, Chamkar Mon, Phnom Penh, Cambodia
Tel: +855 23 215519 / 216295. Fax: +855 23 211339. Website: cambodia.unfpa.org
UNFPA Cambodia @UNFPACambodia UNFPA Cambodia

# សុខភាពបន្តពូជ និងសុខភាពផ្លូវភេទយុវវ័យ

## ផ្អែកតាមលទ្ធផលវិភាគស៊ីជម្រៅលើទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ពីឆ្នាំ២០០០ ដល់ ឆ្នាំ២០១៤

### សេចក្តីផ្តើម

ក្នុងចំណោមប្រជាជនសរុប ១៤.៦លាននាក់ ប្រទេសកម្ពុជាមានចំនួនប្រជាជនវ័យក្មេង អាយុចន្លោះពី១៥-២៤ឆ្នាំ ២១.៦% ដែលធ្វើឱ្យប្រទេសកម្ពុជា ក្លាយជាប្រទេសមានប្រជាជនវ័យក្មេងច្រើនជាងគេ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (ពាក់កណ្តាលជំរឿន ឆ្នាំ២០១៣)។ ប្រជាជនវ័យក្មេង គឺជាធនធានដ៏សំខាន់សម្រាប់បម្រើដល់ការរីកចម្រើន និងការអភិវឌ្ឍវិស័យ សេដ្ឋកិច្ច-សង្គមកិច្ច។ ប៉ុន្តែពួកគេភាគច្រើន កំពុងជួបប្រទះនឹងបញ្ហាប្រឈមធ្ងន់ធ្ងរមួយចំនួន រួមមាន បញ្ហាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទជាដើម ដែលបណ្តាលមកពីកត្តាមួយចំនួន ដូចជា កង្វះខាតព័ត៌មាន និងចំណេះដឹង អំពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សេវាយុវវ័យប្រកបដោយមិត្តភាព ការទទួលបានការអប់រំតិចតួច និងបញ្ហាទេសន្តរប្រវេសន៍។ ក្នុងពេលបច្ចុប្បន្ននេះ ប្រជាជនវ័យក្មេងកាន់តែច្រើនឡើងៗ ឆាប់រហ័សប្រឡូកក្នុងការរួមភេទ។ ទន្ទឹមគ្នានេះ អត្រារៀបការក្នុងចំណោមយុវវ័យដែលមានអាយុចន្លោះពី ១៥-២៤ឆ្នាំ ក៏កំពុងតែកើនឡើងផងដែរ។ តួលេខចំនួនស្រ្តីវ័យក្មេងដែលប្រព្រឹត្តការរួមភេទញឹកញាប់ មិនបានប្រើប្រាស់មធ្យោបាយពន្យារកំណើតកំពុងថយចុះជាលំដាប់ ប៉ុន្តែស្ថិតិជាក់លាក់អំពីស្ថានភាពសុខភាពបន្តពូជ និងសុខភាពផ្លូវភេទរបស់ក្មេងជំទង់ និងយុវវ័យ នៅមិនទាន់មានការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅនៅឡើយទេ។ ឯកសារនេះសង្ខេបព័ត៌មានសំខាន់ៗ អំពីការប្រព្រឹត្តរបស់យុវវ័យពាក់ព័ន្ធនឹងសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ការប្រើប្រាស់មធ្យោបាយពន្យារកំណើត និងចំណេះដឹងអំពីការឆ្លងជំងឺកាមរោគ និងមេរោគអេដស៍ ។

**និយមន័យ:**

**មនុស្សវ័យជំទង់៖** ក្រុមប្រជាជនវ័យក្មេង ដែលមានអាយុចន្លោះពី ១០ ដល់ ១៩ ឆ្នាំ (WHO)

**យុវវ័យ៖** ក្រុមប្រជាជនដែលមានអាយុចន្លោះពី១៥ ដល់ ២៤ ឆ្នាំ

**ប្រជាជនវ័យក្មេងដែលងាយរងគ្រោះបំផុត៖** ក្រុមប្រជាជនវ័យក្មេងដែលងាយរងគ្រោះបំផុត ស្ថិតក្នុងអាយុចន្លោះពី ១៥ ដល់ ៣០ ឆ្នាំ

ភាគរយរបស់ស្រ្តីវ័យក្មេង អាយុចន្លោះពី ១៥ -២៤ឆ្នាំ ដែលរៀបការក្នុងអាយុពិតប្រាកដមួយ




### បញ្ហានានាពាក់ព័ន្ធនឹងសុខភាពបន្តពូជ និងសុខភាពផ្លូវភេទសម្រាប់មនុស្សវ័យជំទង់ និងយុវវ័យ

- អត្រារៀបការក្នុងចំណោមអ្នកមានអាយុចាប់ពី១៥ឆ្នាំដល់២៤ឆ្នាំ ទាំងពីរភេទ បានកើនឡើង (ស្រ្តី កើនពី២៥.៨% ក្នុងឆ្នាំ២០០០ ដល់៣៨.៧% ក្នុងឆ្នាំ២០១៤ រីឯបុរស កើនពី ១៦.៥% ក្នុងឆ្នាំ២០០៥ ដល់១៩.០% ក្នុងឆ្នាំ២០១៤)។
- សមាមាត្រនៃស្រ្តីវ័យក្មេង អាយុចាប់ពី ១៥-១៧ឆ្នាំ ដែលទើបរៀបការរួច មានលំអានដូចៗគ្នា ពោលគឺប្រមាណជា៤%-៦% នៅគ្រប់លទ្ធផលអង្កេតទាំង៤លើក។
- ការយល់ដឹងបានតិចតួចអំពីមធ្យោបាយពន្យារកំណើត និងការយល់ខុសទៅលើផលរំខានរបស់វា ក៏ដូចជាការប្រកាន់ខ្ជាប់នូវផ្នត់គំនិតវប្បធម៌និងសង្គមនានា បូកផ្សំនឹងការដែលស្រ្តីមិនសូវមានអំណាចនៅក្នុងទំនាក់ទំនងប្តីប្រពន្ធ គឺជាកត្តារួមចំណែកធ្វើឱ្យការប្រើប្រាស់មធ្យោបាយពន្យារកំណើតបែបទំនើបមានកម្រិតទាប។
- ក្នុងចំណោមប្រជាជនងាយរងគ្រោះបំផុត អាយុចន្លោះពី១០-២៤ឆ្នាំ មានបុរស ៣៧.៧% និងស្រ្តី ១៨.៥% បានប្រព្រឹតការរួមភេទ នៅអំឡុងពេល៣ខែចុងក្រោយ។
  - ក្នុងចំណោមនេះ មានបុរស ៦៩.៦% និងស្រ្តី ៥២.៥% បានប្រឡូកក្នុងសេវាកម្មផ្លូវភេទ
  - មានបុរស៤៣.៣% និងស្រ្តី៦.៥% តែប៉ុណ្ណោះ ដែលបានរាយការណ៍ថា បានប្រើប្រាស់ស្រោមអនាម័យការពារទៀងទាត់ពេលរួមភេទជាមួយដៃគូរបស់ខ្លួន នៅអំឡុងពេល ៣ ខែ ចុងក្រោយ។

ភាគរយរបស់មនុស្សវ័យក្មេងដែលបានប្រឡូកក្នុងសេវាកម្មផ្លូវភេទ ក្នុងចំណោមក្រុមងាយរងគ្រោះបំផុត ដែលមានអាយុចន្លោះពី ១០-២៤ឆ្នាំ និងបានប្រព្រឹត្តការរួមភេទ ក្នុងរយៈពេល ៣ខែ ចុងក្រោយ




អត្រាលទ្ធភាពបង្កកំណើតតាមក្រុមអាយុរបស់ស្រ្តីវ័យក្មេង នៅតំបន់ទីប្រជុំជន និងជនបទ៖ ពីឆ្នាំ ២០០០ ដល់ ២០១៤




### លទ្ធភាពផ្តល់កំណើតកូនរបស់ក្មេងស្រីវ័យជំទង់:

- លទ្ធភាពផ្តល់កំណើតកូនរបស់មនុស្សវ័យជំទង់ បានធ្លាក់ចុះចំពោះអ្នករស់នៅទីប្រជុំជន តែកើនឡើងចំពោះអ្នករស់នៅទីជនបទ។
  - ស្រ្តីរស់នៅទីជនបទ អាយុចន្លោះពី១៥-២៤ឆ្នាំ ជាង ៣៣% បានក្លាយជាម្តាយវ័យក្មេង នៅក្នុងឆ្នាំ២០១៤។
  - ភ្នំពេញ គឺជាតំបន់ដែលអត្រាលទ្ធភាពផ្តល់កំណើតកូនរបស់មនុស្សវ័យជំទង់មានកម្រិតទាបជាងគេបំផុត នៅក្នុងឆ្នាំ២០១៤ ចំណែកឯតំបន់ភ្នំ/ខ្ពង់រាប មានអត្រាខ្ពស់ជាងគេ។
- ចំនួនស្រ្តីដែលមិនបានចូលរៀន និងក្លាយជាម្តាយនៅវ័យក្មេង បានកើនឡើងទ្វេដងក្នុងរវាងឆ្នាំ២០០០ និង២០១៤ រីឯចំនួនស្រ្តីដែលទទួលបានការសិក្សាខ្ពស់ហើយមានកូន បានថយចុះស្ទើរតែពាក់កណ្តាល។

ការបែងចែកនៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតរបស់ស្រ្តីវ័យក្មេង អាយុចន្លោះពី ១៥ ដល់ ២៤ឆ្នាំ ដែលធ្លាប់រួមភេទ




### ការប្រព្រឹត្តផ្សេងៗពាក់ព័ន្ធសុខភាពបន្តពូជ និងផលវិបាកនានា

- មានស្រ្តីតិចជាង ១% ដែលមិនទាន់រៀបការ បានរាយការណ៍ថា ពួកគាត់បានប្រព្រឹត្តការរួមភេទ ជាមួយដៃគូរបស់ខ្លួន រវាង ឆ្នាំ២០០០ និង២០១៤។
- ក្នុងឆ្នាំ២០០៥ មានបុរសដែលមិនទាន់រៀបការ អាយុចន្លោះពី១៥-១៧ឆ្នាំ ត្រឹមតែ ១.៨%ប៉ុណ្ណោះ បានរាយការណ៍ថាបានប្រព្រឹត្តការរួមភេទ រីឯបុរសស្ថិតនៅចន្លោះអាយុ ១៨-១៩ឆ្នាំ មាន៩.៦% និងចន្លោះអាយុ២០-២៤ឆ្នាំ មាន ២៧.២%។
- ស្រ្តីជាម្តាយដែលស្ថិតនៅវ័យជំទង់ និងមិនទាន់រៀបការភាគច្រើន មានកូនដោយចៃដន្យ ដែលកត្តានេះនាំឱ្យគាត់សម្រេចចិត្តធ្វើការរំលូតកូន។
- ស្រ្តីវ័យជំទង់មានកូនដោយមិនទាន់រៀបការ ទទួលរងការប៉ះពាល់ពីជំងឺស្លេកស្លាំង គ្រុនចាញ់ និងកាមរោគ ការធ្លាក់ឈាមក្រោយសម្រាល ជំងឺពាក់ព័ន្ធនឹងមាតុភាព និងជំងឺផ្លូវចិត្ត (ជំងឺធ្លាក់ទឹកចិត្ត) មានកំណើនខ្ពស់។
- ការប្រឡូកក្នុងការរួមភេទមុនពេលរៀបការចំពោះស្រ្តីវ័យក្មេង កម្រកើតមានណាស់ គឺខុសពីបុរស ដែលការរួមភេទមុនពេលរៀបការកំពុងតែកើនឡើងជាលំដាប់។
- ស្រ្តីវ័យក្មេងដែលប្រព័ន្ធប្រដាប់បន្តពូជ និងប្រព័ន្ធការពារភាពស៊ាំនៃរាងកាយ មិនទាន់លូតលាស់គ្រប់លក្ខណៈនៅឡើយ ងាយប្រឈមនឹងការឆ្លងជំងឺកាមរោគ និងមេរោគអេដស៍។ កត្តានេះបានធ្វើឲ្យស្រ្តីវ័យក្មេងប្រឈមនឹងបញ្ហាផ្សេងៗដែលបណ្តាលមកពីការមានផ្ទៃពោះ និងសម្រាលកូន ហើយដែលបញ្ហានេះមិនសូវកើតឡើងចំពោះស្រ្តីពេញវ័យទេ។

### ការពន្យារកំណើត

- រវាងឆ្នាំ២០០០ និង២០១៤ អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើត ក្នុងចំណោមស្រ្តីវ័យក្មេង អាយុចន្លោះពី១៥-១៩ឆ្នាំ និង២០-២៤ឆ្នាំ ដែលប្រព្រឹត្តការរួមភេទញឹកញាប់ មានការប្រែប្រួល។
- ក្នុងឆ្នាំ ២០០០ មានស្រ្តី ១២% ដែលមានអាយុចាប់ពី ២០-២៤ឆ្នាំ បានកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតបែបទំនើបប្រភេទណាមួយ ធៀបនឹងឆ្នាំ ២០១៤ ដែលមាន ៣៣%។
- ក្នុងឆ្នាំ២០០០ ស្រ្តី ៣% ដែលមានអាយុចន្លោះពី ២០-២៤ឆ្នាំ បានប្រើប្រាស់មធ្យោបាយពន្យារកំណើតតាមបែបធម្មជាតិ ធៀបនឹងឆ្នាំ ២០១៤ ដែលមាន ១៣%។
- អត្រាមិនទទួលបានសេវាពន្យារកំណើតភាគច្រើន រាយការណ៍ដោយស្រ្តីដែលធ្លាប់រៀបការ ដែលមានអាយុចន្លោះពី ១៥-២៤ឆ្នាំ ធៀបនឹងស្រ្តីដែលមិនធ្លាប់រៀបការ។
- សមាមាត្រនៃចំនួនស្រ្តីដែលធ្លាប់រៀបការ អាយុចន្លោះពី១៥-២៤ឆ្នាំ ហើយមិនទទួលបានសេវាពន្យារកំណើតមានជិត ៣០% (១៥-១៧, ១៨-១៩ និង២០-២៤) នៅឆ្នាំ២០១៤ ។
  - ថ្វីបើយ៉ាងនេះក្តី ក្នុងឆ្នាំ ២០១៤ នេះ តួលេខបែងចែកតាមក្រុមអាយុនិមួយៗមានការធ្លាក់ចុះ គឺ ៥.៦% ចំពោះស្រ្តីមានអាយុចន្លោះពី ១៥-១៧ឆ្នាំ ១.៨% ចំពោះស្រ្តីមានអាយុចន្លោះពី ១៨-១៩ឆ្នាំ និង២.៣% ចំពោះស្រ្តីមានអាយុចន្លោះពី ២០-២៤ឆ្នាំ។

អាយុជាមធ្យមនៃដៃគូចុងក្រោយរបស់ស្រ្តីវ័យក្មេង តាមក្រុមអាយុ៖ ពីឆ្នាំ ២០១០ ដល់ ២០១៤




### ដៃគូរួមភេទចុងក្រោយ

- នៅពេលស្រ្តីមានអាយុកាន់តែច្រើន នោះគម្លាតអាយុខុសគ្នា រវាងស្រ្តី និងដៃគូរបស់គាត់ក៏មានទំហំតូចដែរ។
- ជាមធ្យម ស្រ្តីដែលប្រព្រឹត្តការរួមភេទញឹកញាប់ អាយុចន្លោះពី១៥-១៧ឆ្នាំ មានគម្លាតអាយុខុសគ្នា៦ឆ្នាំ ហើយចំពោះចន្លោះអាយុចាប់ពី២០-២៤ឆ្នាំវិញ មាន៤ឆ្នាំ ធៀបនឹងដៃគូរបស់គាត់។
- ស្រ្តីវ័យក្មេងស្ទើរតែទាំងអស់បានរាយការណ៍ថា ដៃគូរួមភេទរបស់ខ្លួន គឺជាប្តី ឬដៃគូរស់នៅជាមួយគ្នា ដែលខុសពីបុរសមានត្រឹម បីភាគបួន ប៉ុណ្ណោះ។

### ចំណេះដឹងអំពីជំងឺកាមរោគ មេរោគអេដស៍ និងការប្រើប្រាស់ស្រោមអនាម័យការពារ

ភាគរយនៃស្រ្តីវ័យក្មេង អាយុចន្លោះពី ១៥ ដល់ ២៤ឆ្នាំ ដែលមានចំណេះដឹងទូលំទូលាយ អំពីគ្រោះថ្នាក់នៃមេរោគអេដស៍




- ក្នុងឆ្នាំ២០០៥ ភាគរយនៃបុរសដែលបានរាយការណ៍ថា មានដៃគូរួមភេទចុងក្រោយរបស់ខ្លួនជាស្រ្តីប្រកបសេវាកម្មផ្លូវភេទ មាន ១៧.៣% និងបានធ្លាក់ចុះមកត្រឹម ២.២% ក្នុងឆ្នាំ២០១៤។
- ភាគរយនៃអត្រាប្រើប្រាស់ស្រោមអនាម័យការពារក្នុងអំឡុងពេលរួមភេទ ក្នុងចំណោមបុរសវ័យក្មេង អាយុចន្លោះពី១៥-២៤ឆ្នាំ បានថយចុះខ្លាំងគួរឱ្យកត់សម្គាល់។
  - ក្នុងឆ្នាំ២០០៥ អត្រាប្រើប្រាស់ស្រោមអនាម័យក្នុងពេលរួមភេទ នៅតាមទីប្រជុំជន មាន ៥៧.៧% និង ២៣.៣% នៅតាមតំបន់ជនបទ។ នៅក្នុងឆ្នាំ២០១៤ តួលេខនេះ បានធ្លាក់ចុះមកត្រឹម ៥៧.២% នៅទីប្រជុំជន និង ១០.៣% នៅតាមតំបន់ជនបទ។